# សុន្ទរកថា

## លោក ផុន យុទ្ធ សក្ការា តំណាងអង្គការសង្គមស៊ីវិលធ្វើការប្រយុទ្ធនឹងមេរោគអេដស៍ នាពិធីយុទ្ធនាការអប់រំផ្សព្វផ្សាយក្នុងព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និង សំពះព្រះខែ

## ២០ វិច្ឆិកា ២០១០

- សូមគោរព ឯកឧត្តមវេជ្ជ. នុត សុខុម ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ !
- សូមគោរព ឯកឧត្តមវេជ្ជ. តែង គន្នី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ !
- សូមគោរព ឯកឧត្តម ចាន់ សំអាន ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ !
- ឯកឧត្តម លោក ជំទាវ ភ្ញៀវជាតិ អន្តរជាតិ លោក លោកស្រីតំណាងម្ចាស់មូលនិធិ ដៃគូអភិវឌ្ឍន៍ និងតំណាង អង្គការជាតិ និងអន្តរជាតិជាទីគោរព រាប់អាន !
- បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ ដែលមានវត្តមាននៅទីនេះជាទីស្រឡាញ់រាប់អាន !
- ប្អូនៗ ក្មួយៗជាអ្នកស្ម័គ្រចិត្ត ដែលមានវត្តមាននៅទីនេះជាទីស្រឡាញ់រាប់អាន !

ក្នុងនាមតំណាងឱ្យអង្គការសង្គមស៊ីវិល ដែលកំពុងតែអនុវត្តន៍កម្មវិធីអេដស៍នៅប្រទេសកម្ពុជា ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាគណៈអធិបតីក្នុងពិធីបើកយុទ្ធនាការ អប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍ នៅក្រោមប្រធានបទ **សប្បាយ និងសុវត្ថិភាព** ។ នៅក្នុងប្រធានបទនេះមានន័យថា យើងមកសប្បាយប្រកបដោយសុវត្ថិភាព ដោយសន្យាមិនយកមេរោគអេដស៍មកចម្លងខ្លួន និងអ្នកដែលជាទីស្រឡាញ់របស់យើង ។

ថ្ងៃនេះ ជាថ្ងៃដ៏វិសេសវិសាលបំផុត ដោយយើងទាំងអស់គ្នាបានប្រារព្ធពិធីនេះឡើង ក្នុងគោលបំណងអប់រំផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ដល់ប្រជាពលរដ្ឋដែលមកចូលរួមទស្សនាក្នុង ព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែ និងក៏ជាសារមួយប្រកបដោយអត្ថន័យដល់ប្រជាជនកម្ពុជាគ្រប់រូប។ នៅក្នុងយុទ្ធនាការអប់រំផ្សព្វផ្សាយនេះ មានសកម្មភាពជាច្រើនដែលអង្គការសង្គមស៊ីវិល បានសហការជាមួយរាជរដ្ឋាភិបាល ហើយដែលសកម្មភាពទាំងអស់នោះរួមមានៈ ការចុះអប់រំផ្ទាល់ ការរៀបចំកម្មវិធី សំដែងនៅលើឆាក ការផ្តល់ប្រឹក្សានិងការធ្វើតេស្តឈាមរកមេរោគអេដស៍ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍

និងការបោះពុម្ពសំភារៈអប់រំផ្សព្វផ្សាយផ្សេងៗ ។ ជាងនេះទៅ ទៀត យើងក៏មានអ្នកស្ម័គ្រចិត្តចំនួនជាង៦០០នាក់ ដែលនឹងត្រូវធ្វើការចែកចាយខិតប័ណ្ណអប់រំផ្សព្វផ្សាយពីការ បង្ការមេរោគអេដស៍និងជំងឺអេដស៍ចំនួន ៥.០០០ សន្លឹក ប្រតិទិនផ្ទាំងធំឆ្នាំ២០១១ចំនួន៥.០០០ ស្រោមអនាម័យចំនួន៤៥០.០០០ស្រោម អាវយឺតចំនួន ៧.០០០ អាវ និងសំភារៈអប់រំផ្សព្វផ្សាយមួយចំនួនផ្សេងទៀត នឹងត្រូវយកមកប្រើប្រាស់ក្នុងយុទ្ធនាការអប់រំផ្សព្វផ្សាយក្នុងរយៈពេលបីថ្ងៃនេះ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្អូនៗ និងក្មួយៗ ទាំងអស់ជាទីគោរព រាប់អាន!**

ថ្មីៗនេះប្រទេសកម្ពុជាយើងទើបតែបានទទួលនូវពានរង្វាន់អភិវឌ្ឍន៍សហស្សវត្សរ៍ គោលដៅទី ៦ ឆ្លើយតបទៅនឹងមេរោគអេដស៍ ហើយការដែលទទួលបានពានរង្វាន់នេះគឺជាសក្ខីភាពមួយដែលបង្ហាញនូវភាពជោគជ័យនៅលើឆាកអន្តរជាតិ ក្នុងភាពជាអ្នកដឹកនាំជាតិ ការប្តេជ្ញាចិត្តខ្ពស់ និងវឌ្ឍនភាពឆ្លើយតបទៅនឹងការប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា ហើយភាពជោគជ័យទាំងនោះបានដោយមានការចូលរួមយ៉ាងសកម្មពីរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អ្នកដែលទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ដៃគូអភិវឌ្ឍន៍ ព្រមទាំងម្ចាស់ជំនួយ ។

ទន្ទឹមនឹងភាពជោគជ័យទាំងអស់នេះ ក្នុងនាមជាតំណាងអង្គការសង្គមស៊ីវិល យើងក៏មានការព្រួយបារម្ភផង ដែរនូវឧបសគ្គធំៗមួយចំនួនទៀត ដែលយើងកំពុងនឹងប្រឈមមុខនាពេលបច្ចុប្បន្ននេះ ដូចជាៈ ការកើនឡើងនៃចំនួនដែលជាជនប្រឈមមុខខ្ពស់ ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ក្រុមបុរសស្រឡាញ់បុរស និងស្ត្រីបំរើតាមសេវាកម្សាន្តសប្បាយ ។ លើសពីនេះទៀត ការចម្លងមេរោគអេដស៍ក្នុងគ្រួសារ ពីស្វាមីទៅភរិយា ការចម្លងពីម្តាយទៅទារក ការមាក់ងាយនិងការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍នឹងក្រុមប្រឈមមុខខ្ពស់ ភាពខ្វះចន្លោះក្នុងការអនុវត្តន៍ច្បាប់ ការឆាប់ប្រលូកក្នុងការរួមភេទក្នុងចំណោមយុវវ័យ ការកើនឡើងនៃអ្នកចំណាកស្រុក និងការធ្លាក់ចុះនៃការប្រើប្រាស់ស្រោមអនាម័យ ដែលបញ្ហាទាំងអស់នេះគឺជាការព្រួយបារម្ភ និងជាកង្វល់មួយបន្ថែមទៀតនូវការលេចឡើងនូវរលកទី២នៃការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា ។

ក្នុងនាមអង្គការសង្គមស៊ីវិលដែលកំពុងបំពេញការងារប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមធ្វើការសំណូមពរយ៉ាងទទូចដល់ដៃគូអភិវឌ្ឍន៍ និងម្ចាស់មូលនិធិទាំងអស់ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាបង្កើនការប្តេជ្ញាចិត្ត

ខ្ពស់ ក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសរកយន្តការប្រកបដោយប្រសិទ្ធិភាព ដោយចលនាគៀងគរប្រភពធនធានពីសហគមនជាតិ និងអន្តរជាតិ និងធ្វើការពង្រឹងការដឹកនាំពីគ្រប់ស្ថាប័នដែលជាប់ពាក់ពន្ធ័ទាំងអស់ដើម្បីធានានូវការឆ្លើយតបដោយប្រសិទ្ធិភាព និរន្តរភាព និងចំទិសដៅដែលជាអាទិភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នៅប្រទេសកម្ពុជា។ ខាងក្រោមនេះ ជាសំណូមពរមួយចំនួនដែលអង្គការសង្គមស៊ីវិលសូមលើកឡើងដើម្បីធ្វើការពិចារណា ក្នុងបទអន្តរាគមន៍ប្រយុទ្ធនឹងជំងឺអេដស៍:

- បង្កើន និងលើកកំពស់កិច្ចអន្តរាគមន៍បង្ការចំពោះក្រុមដែលងាយរងគ្រោះ
- ការលើកកំពស់ការអប់រំពីយេនឌ័រ និងយន្តការការពារមេរោគអេដស៍ ដែលផ្តល់សិទ្ធិជាម្ចាស់ដល់ស្ត្រីដើម្បីការពារខ្លួនជៀសផុតពីការឆ្លងមេរោគអេដស៍
- បន្ត ពង្រឹង និងពង្រីកកម្មវិធីថែទាំ និងគាំទ្រដល់អ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ដោយធានាឱ្យបានថាអ្នករស់នៅជាមួយមេរោគអេដស៍នៅតំបន់ជនបទដាច់ស្រយាលបានទទួលនូវសេវាថែទាំ សុខភាពប្រកបដោយគុណភាព និងមានសុវត្ថិភាពស្បៀងអាហារ
- បង្កើនការទំនាក់ទំនង និងការប្តេជ្ញាចិត្តរបស់ស្ថាប័នដែលពាក់ពន្ធ័ ដើម្បីលើកកំពស់លទ្ធភាពរកប្រាក់ចំណូលសំរាប់អ្នករស់នៅជាមួយមេរោគអេដស៍
- ធ្វើការលុបបំបាត់ការមាក់ងាយ និងការរើសអើងដែលរាំងស្ទះដល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះមេរោគអេដស៍ដោយធ្វើការអនុវត្តន៍ និងកែប្រែគោលនយោបាយ ច្បាប់ និងបទបញ្ជាផ្សេងៗ
- បង្កើនឆន្ទះនយោបាយដែលគាំទ្រ និងការពារសិទ្ធិរបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងជនដែលងាយរងគ្រោះខ្ពស់បំផុត
- លើកកម្ពស់ឱ្យមានការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិល អ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍និងក្រុមដែលងាយរងគ្រោះបំផុតក្នុងការបង្កើតច្បាប់ គោលនយោបាយនានាដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីផ្នែកឯកជនក្នុងការឆ្លើយតបទៅនឹងការងារអេដស៍

- បង្កើនប្រភពធនធាន និងយន្តការគៀងគររកជំនួយជាមួដៃគូ និងស្ថាប័នដែលជាប់ពាក់ពន្ធ័ទាំងអស់ដើម្បីធានាឱ្យបាននូវប្រភពធនធានគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងការប្រយុទ្ធនឹងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធិភាព ។

គណៈកម្មាធិការសំរបសំរួលប្រយុទ្ធនឹងជំងឺអេដស៍ សូមធ្វើការប្តេជ្ញាចិត្តចូលរួមជាមួយថ្នាក់ជាតិ និងសហគមន៏ទាំងអស់ ក្នុងការងារប្រយុទ្ធនឹងការរីករាលដាលនៃជំងឺអេដស៍ ដោយជួយបំពេញនូវភាពចន្លោះខ្វះខាតរបស់រាជរដ្ឋាភិបាលតាមរយៈការចូលរួមកសាងផែនការ ការអនុវត្ត ការតាមដាន ការកសាងសមត្ថភាព ការពង្រឹងនូវយន្តការដែលមានស្រាប់ ដើម្បីធានាឱ្យបាននូវការឆ្លើយតបអោយមានប្រសិទ្ធភាព និរន្តរភាព និងភាពជោគជ័យនូវផែនការដែលបានគ្រោងទុក ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការសង្គមស៊ីវិលដែល បានចូលរួមទាំងកំលាំងកាយ ថវិកា និងសំភារៈដើម្បីចូលរួមក្នុងការរៀបចំកម្មវិធីនេះរួមមាន អង្គការ : PSI, KHANA, Inthanou, AHF, CRC, CHEC, CHEMS, UNFPA, BC, CCODP, CAFOD, MSIC, Maryknoll, ACTED/PSF និង TASK ព្រមទាំងអង្គការដែលមានកម្មវិធីចុះ អប់រំផ្សព្វផ្សាយ និងមានកម្មវិធីសំដែងនៅលើឆាកមានដូចជាអង្គការៈ ACTED/PSF, CHEC, CSSD, KYA, CCW, WNU, HOPE, SFODA, SIT, TASK, SMO, RHAC, MISC, NEYMO, CRC, YCC, និង AHF ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំបាទសូមអំពាវនាវជូនដល់ប្រជាពលរដ្ឋដែលនឹងមកទស្សនាក្នុងព្រះរាជពិធី បុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែទាំងអស់ ប្រសិនបើមានចំងល់ និងចង់ស្វែងយល់ពីមេរោគអេដស៍ឱ្យកាន់តែច្បាស់ សូមបងប្អូនមេត្តាអញ្ជើញមកកាន់ទីនេះ ឬក៏ធ្វើការទំនាក់ទំនងជាមួយភ្នាក់ងារអប់រំផ្សព្វផ្សាយរបស់យើង ដែលមានពាក់អាវយឺតព្រមជាមួយនិងសារ សប្បាយ និងសុវត្ថិភាព ។

ជាចុងបញ្ចប់ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗ ទាំងអស់នៃអង្គពិធីទាំងមូល សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងប្តេជ្ញារួមគ្នាសម្រេចឱ្យបាននូវការប្រយុទ្ធ និងឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ។

**សូមអរគុណ!**